# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤។

**២. ទីកន្លែង ៖** តាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលចូលរួមតាមប្រព័ន្ធនិម្មិតចំនួន៥០រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពីការអនុវត្តថវិការបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដែលបង្ហាញដោយ **លោក ឌុច ម៉ុងស៊ីតាណា** អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំ និងបានបញ្ជាក់ពីការអនុវត្តថវិការបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយបានអនុវត្តសាកល្បងជំហានដំបូងលើរាជធានី ខេត្ត អាទិភាព

ចំនួន៤ រួមមានរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប គ្រោងថវិកា ៨០លានរៀលនៅឆ្នាំ២០២១ បន្ទាប់មកអនុវត្តលើខេត្តចំនួន១១ទៀត គ្រោងថវិកា៦០លានរៀល នៅឆ្នាំ២០២៣ និងគ្រោងថវិកា៤០លានរៀល សម្រាប់ខេត្តចំនួន១០បន្តទៀត ។ ហេតុដូច្នេះ តើយើងគួររកវិធីសាស្ត្រឬមធ្យោបាយយ៉ាងណា ដើម្បីសម្រេចគោលដៅ៩៥ទីមួយនៅឆ្នាំ២០២៥។ បទអន្តរាគមន៍បង្ការដែលមានលក្ខណៈសុក្រឹតជាក់លាក់ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលាដែលផ្តោតទៅលើគោលនយោបាយលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍សម្រេចគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

កិច្ចប្រជុំនេះបានផ្តោតលើការពិនិត្យលើបទពិសោធន៍ក្នុងការអនុវត្តថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត។

ជាបន្ត **លោក ឌុច ម៉ុងស៊ីកាណា** អនុប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញពីការអនុវត្តថវិការបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តមានបួនចំនុចៈ

**១. ការរៀបចំគម្រោងថវិកា** តាំងពីឆ្នាំ២០២១កន្លងមករហូតមកដល់ឆ្នាំ២០២៤នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាតាមខេត្តនីមួយៗជាដំណាក់កាលគឺៈ

- នៅឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាសាកល្បងជំហានដំបូងសម្រាប់អនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត អាទិភាពចំនួន៤ខេត្ត រួមមានរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ដែលមានថវិកា៨០លានរៀល ក្នុងមួយខេត្ត។

- នៅឆ្នាំ២០២៣ ក្រសួងបានផ្តល់ថវិកាសម្រាប់អនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តចំនួន១១ខេត្តទៀតមានដូចជា ខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន និងខេត្តកំពង់ធំ មានថវិកា៦០លានរៀល ក្នុងមួយខេត្ត។

- នៅឆ្នាំ២០២៤ ក្រសួងបានផ្តល់ថវិកាសម្រាប់អនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តចំនួន១០ខេត្តថែមទៀតមានដូចជា ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តកោះកុង ខេត្តស្វាយរៀង ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តកែប ខេត្តឧត្តរមានជ័យ និងខេត្តកំពត មានថវិកា៤០លានរៀល ក្នុងមួយខេត្ត។

ចំពោះមុខសញ្ញាចំណាយនៃកញ្ចប់ថវិកាដែលត្រូវចំណាយមាន៣សកម្មភាពគឺ សម្រាប់កិច្ចប្រជុំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល និងប្រាក់បេសកកម្ម។

**២. ការអនុវត្តថវិកា** ការអនុវត្តថវិកាប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅរាជធានី ខេត្ត ត្រូវអនុវត្តថវិកាចំណាយគាំទ្រសកម្មភាពការងាររបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដែលបានគ្រោងក្នុងសៀវភៅថវិកាឆ្នាំ២០២៤ តាមមុខសញ្ញាចំណាយ ដែលមានអភិបាល ឬអភិបាលរងរាជធានី ខេត្ត ជាប្រធានដោយមាននាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ជាសេនាធិការ។ ទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវប្រមូលលិខិតឯកសារយុត្តិការ និងសក្ខីបត្រចំណាយលើសកម្មភាពខាងលើជាមូលដ្ឋានសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

**៣. នីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មមាន** បេសកកម្មនៅក្នុងប្រទេស និងបេសកកម្មនៅក្រៅប្រទេស ការអនុវត្តថវិកានោះទៅតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងតាមនីតិវិធីទូទាត់ត្រង់ ហើយសាច់ប្រាក់ក៏ត្រូវទទួលបានទៅតាមឋានៈ តួនាទីដែលរដ្ឋាភិបាលបានកំណត់។

**៤. នីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ**

គោលបំណង កំណត់អំពីវិធាន និងនីតិវិធីអនុវត្តចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំក្នុងក្របខណ្ឌនៃឥណទានថវិកាអនុគណនី៦១០៤១ "សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស" និងអនុគណនី៦១១០៣ "ប្រជុំ សិក្ខាសាលា និងសន្និសីទ" ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព ភាពទាន់ពេលវេលានៃការរៀបចំ និងការអនុវត្តចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កន្លងមកសម្រាប់រាជធានី ខេត្ត ចំនួន៤ ដែលទទួលបាន៨០លានរៀល ចាប់ពីឆ្នាំ២០២១ គណៈកម្មាធិការ ប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត បានអនុវត្តថវិកាមួយរយភាគរយ។ ចំពោះខេត្ត១១ ដែលទទួលបាន ៦០លានរៀលក្នុងឆ្នាំ២០២៣ មានតែ៧ខេត្តទេដែលបានអនុវត្ត មានខេត្តតាកែវ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និង ខេត្តដែលមិនបានអនុវត្ត ថវិកា៦០លានរៀលមាន ខេត្តកំពង់ធំ ខេត្តព្រះសីហនុ ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ។ រីឯខេត្តទទួលបាន ៤០លានរៀលនៅឆ្នាំ២០២៤ មិនទាន់បានអនុវត្តថវិកានៅឡើយ មានខេត្តស្វាយរៀង ខេត្តកំពត ខេត្តកោះកុង ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តកែប និងខេត្តឧត្តរមានជ័យ។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំមានប្រសាសន៍ថា តាមកិច្ចប្រជុំកន្លងមកសម្រាប់រាជធានី ខេត្ត មិនមានថវិកាសម្រាប់អនុវត្តសកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ទេ។ យោងស្មារតីនៃកិច្ចប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្រេចផ្តល់ការនេះដល់អគ្គលេខាធិការដ្ឋានសហការជាមួយនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋាន រតនាគារជាតិ ដើម្បីពិភាក្សាពីវិធីអនុវត្តថវិកាសម្រាប់ថ្នាក់ក្រោម។ ម្យ៉ាងទៀតត្រូវពង្រឹង

ភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានថ្លែងនូវអំណរគុណដល់សមាជិកអង្គប្រជុំដែលបានចូលរួម ព្រមទាំងផ្តល់ជាគុចូល និងជូនពរឱ្យជួបនឹងពុទ្ធពរបួនប្រការកុំបីឃ្លាតឡើយ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤

**បានពិនិត្យត្រឹមត្រូវ**

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ**

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**ស៊ុំ ផល្លា**

**វេជ្ជ. ហួត សេរីរដ្ឋ**

**បណ្ឌិត ឈឹម ឃិនជារ៉េត**